# ខ្លឹមសារសង្ខេបអត្ថបទ

Immunities, John L. Diamond and et al., Understanding Torts, 5th Ed., 2013, pp.242-247

១. អភ័យឯកសិទ្ធិ (immunity) មាននៅក្នុងវិស័យជាច្រើន។ នៅក្នុងការទទួលខុសត្រូវលើអំពើអនីត្យានុកូល (tort) អភ័យឯកសិទ្ធិការពារ ចុងចម្លើយពីការទទួលខុសត្រូវលើអំពើអនីត្យានុកូល។ នេះវាផ្អែកលើមូលហេតុគោលនយោបាយសំខាន់។

២. អភ័យឯកសិទ្ធិចែកជា អភ័យឯកសិទ្ធិការងារមនុស្សធម៌ (charitable immunity: CI) អភ័យឯកសិទ្ធិសហព័ទ្ធ (spousal immunity: SI) អភ័យឯកសិទ្ធិរវាងកូននិងម្ដាយឪពុក (child-parent immunity: CPI) អភ័យឯកសិទ្ធិរដ្ឋាភិបាល (governmental immunity: GI)។

៣. អង្គការមនុស្សធម៌ មានអភ័យឯកសិទ្ធិ តែឥឡូវលែងមានហើយ មានន័យថា ពួកគេនឹងទទួលខុសត្រូវ ប្រសិនបានប្រព្រឹត្តអំពើអនីត្យានុកូល។ ការទទួលបាន CI ដោយសារ វាជាការងារជួយសហគមន៍, ក្នុងមូលហេតុជាក់លាក់ និងចុងក្រោយ គេបានសន្មត់ថា អ្នកទទួលទាន បានបោះបង់សិទ្ធិប្ដឹង។ សម្រាប់ SI, ប្ដីឬប្រពន្ធមិនអាចប្ដឹងគ្នាបានទេ ព្រោះពួកគេមានអត្តសញ្ញាណគតិយុត្តរួមគ្នា ហើយប្រសិនបើកឲ្យមានការប្ដឹង នោះភាពសុខុដុមនៃអាពាហ៍ពិពាហ៍អាចនឹងរង្គោះរង្គើ។ ទោះបីជាយ៉ាងនេះក្ដី SI ត្រូវលើកចោលក្នុងរដ្ឋជាច្រើននៃសហរដ្ឋអាមេរិក។ ខុសពី SI, CPI នៅតែមានក្នុងយុត្តាធិការជាច្រើន នេះដោយសារថា តុលាការ មានភាពស្ទាក់ស្ទើរក្នុងការត្រួតពិនិត្យ (judicial review) លើការងារថែទាំងរបស់ម្ដាយ លើកុមារ។

៤. ក្នុងសម័យដើម GI គឺលក្ខណៈពេញលេញ ហើយរដ្ឋាភិបាល ត្រូវបានការពារ ដោយអភ័យឯកសិទ្ធិពីបណ្ដឹង នៃអំពើអនីត្យានុកូលណាមួយ។ វាទាញចេញពីទ្រឹស្ដីកំមុនឡ «ការហាមឃាត់បណ្ដឹងប្រឆាំងស្ដេច» (នាពេលនោះស្ដេចដឹកនាំ)។ ការងាររដ្ឋាភិបាល គឺរៀបចំ និងអនុវត្តសេចក្ដីសម្រេចគោលនយោបាយ ដូចនេះ តុលាការមិនអាច ត្រួតពិនិត្យនូវ សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ ដែលកើតជាអំពើអនីត្យានុកូលទេ។ ការធ្វើផ្ទុយពីនេះ អាចប៉ះដល់គោលការណ៍បែងចែកអំណាច។ ក្រោយមកមានភាពប្រែប្រួល សាកលវិទ្យាល័យរដ្ឋ មិនមានអភ័យឯកសិទ្ធិលើ ការខកខានរបស់អ្នកព្យាបាល (ប្រចាំសាកលវិទ្យាល័យ) ក្នុងការព្រមានជនរងគ្រោះ អំពីចេតនាមនុស្សឃាតនៃអ្នកជំងឺរបស់ខ្លួន។ ដូចនេះ ការទទួលបានអភ័យឯកសិទ្ធិមានក្នុងកម្រិតជាក់លាក់ ដូចជា ការជ្រៀតជ្រែកក្នុងសិទ្ធិកិច្ចសន្យា (interference with

contract rights)។ រដ្ឋាភិបាលដែនដី មិនមានអភ័យឯកសិទ្ធិ ក្នុងករណីដែលសកម្មភាពអាជីវកម្មឯកជន មានការចូលរួមដោយរដ្ឋាភិបាលដែនដី ហើយបានប្រព្រឹត្តអំពើអនីត្យានុកូល។

**ខ្លឹមសារដកស្រង់៖** រដ្ឋជាច្រើន ឥឡូវនេះបានលុបចោលនូវ ទ្រឹស្តីកំមុនឡ ស្តីពីអភ័យឯកសិទ្ធិរដ្ឋាភិបាល ហើយភាគច្រើន បានធ្វើច្បាប់ស៊ីជម្រៅ ដែលគ្រប់គ្រងលើការទទួលខុសត្រូវលើអំពើអនីត្យានុកូលរបស់ភ្នាក់ងាររដ្ឋ និងភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន (ទំ. ២៤៦)។

**ពាក្យគន្លឹះ៖** ការទទួលខុសត្រូវលើអំពើអនីត្យានុកូលភាព, អភ័យឯកសិទ្ធិ